# ទំនុកដាក់បណ្ដាសា[1]

## អត្ថន័យនៃទំនុកដាក់បណ្ដាសា

ឈ្មោះដែលបានបញ្ជាក់មួយចំនួននៅក្នុងទំនុកដំកើងដែលមានការជំនុំជំរះយ៉ាងអាក្រក់លើ**ខ្មាំងសត្រូវ** របស់អ្នកនិពន្ធ។ ពាក្យ "**បណ្ដាសា**" បានប្រាប់ថា អ្នកនិពន្ធបានអធិស្ឋានសូមឲ្យការអាក្រក់កើតមានដល់អ្នក ធ្វើទុក្ខពួកគេ។ វាគឺជាពាក្យធ្ងន់ៗ ប្រហែលវាមិនមែនជាពាក្យល្អនោះឡើយ។ "ទំនុកនៃសេចក្ដីក្រោធ" ប្រហែល ជាឃ្លាដែលប្រសើរជាង ប៉ុន្ដែពាក្យ **ទំនុកដាក់បណ្ដាសា** គឺជាពាក្យដែលត្រូវស្ដង់ដាជាង ហើយគេប្រើពាក្យនេះ ជាប្រយោជន៍នៃការធ្វើចំណែកថ្នាក់ និងសម្រាប់ប្រពៃណី យើងនឹងប្រើវា នៅពេលដែលសំដៅលើក្រុមនៃកំ ណាព្យនេះ។ យ៉ាងហោចណាស់មានទំនុកចំនួន៧ ដែលចូលទៅក្នុងក្រុមនេះ ដែលអស្ចារ្យជាង ឬមានកំរិតតិច ជាង៖ ទំនុក៣៥, ៥៥, ៥៩, ៦៩, ៧៩, ១០៩, និង១៣៧។ នៅក្នុងចំណោមទំនុកទាំង៧នេះ ទំនុក៣៥, ៦៩, និង ១០៩ គឺមាននិយាយខ្លាំងក្លាជាង ហើយទំនុកផ្សេងទៀតនិយាយទៅតាមផ្ទៃរឿង ហើយក៏ជួយឲ្យយើងអាចកំ ណត់ប្រភេទនៃទំនុកបាន។

### បញ្ហា

អស់អ្នកណាដែលអានទំនុកដំកើងដោយភ្នែកស្ទាក់ស្ទើរ នឹងរកឃើញការនិយាយរិះគន់មួយចំនួនចំពោះខ្មាំងសត្រូវរបស់អ្នកនិពន្ធ។ ពាក្យប្រៀបធៀបរបស់អ្នកនិពន្ធបានឆក់យកមនុស្សប្រភេទនេះ ទាំងពួកជនបរទេស និងនៅក្នុងស្រុក នៅក្នុងរូបភាពរបស់ពួកគេដូចជា "សិង្ហ" (៣៥:៧) ឬ "គេលូ....ជាឆ្កែ" ដែលដើរក្រ វែលទីក្រុង (៥៩:៦,១៤-១៥)។ ការអាក្រក់របស់ពួកគេបានបង្ហាញថាខ្លួនរបស់ពួកជា "មនុស្សដែលកំចាយឈាម" (៥៩:២) នៅខណៈពេលដែលពួកគេធ្វើសកម្មប្រយុទ្ធ អាចនឹងឮថាពាក្យរបស់ពួកគេ "សុទ្ធតែជាដាវហូតស្រាប់" (៥៥:២១)។ នៅក្នុងភាសាប្រឆាំងទាស់ទៅនឹងពួកសត្រូវរបស់អ្នកនិពន្ធ ដោយបង្ហាញពីជម្ងឺជាច្រើនដែលនឹងកើតដក់ពួកគេ គឺជាទំរង់នៃសេចក្ដីអធិស្ឋានទៅកាន់ព្រះជាម្ចាស់សូមឲ្យទ្រង់នាំយកការអាក្រក់ យ៉ាងសហ័សមកលើពួកគេ។ សំនួរដែលអ្នកអានកណ្ឌទំនុកដំកើងអាចនឹងសួរបានថា តើសេចក្ដីស្រឡាញ់ របស់ព្រះជាម្ចាស់នៅទីណានៅក្នុងការមើលងាយបែបនេះ? សេចក្ដីបង្រៀនរបស់ព្រះយេស៊ូវថា ចូរឲ្យស្រ ឡាញ់ខ្មាំងសត្រូវរបស់អ្នក៖ "ចូរស្រឡាញ់អ្នកជិតខាងឯង តែស្អប់ខ្មាំងសត្រូវឯងវិញ ប៉ុន្ដែខ្ញុំប្រាប់ថាត្រូវស្រ ឡាញ់ពួកខ្មាំងសត្រូវ ត្រូវឲ្យពរដល់អ្នកណាដែលប្រទេចផ្ដាសា ត្រូវប្រព្រឹត្ដល្អនឹងអ្នកណា ដែលស្អប់អ្នករាល់ គ្នា ហើយត្រូវអធិស្ឋាន ឲ្យអ្នកណាដែលធ្វើទុក្ខបៀតបៀនដល់អ្នករាល់គ្នាវិញ ដើម្បីឲ្យបានធ្វើជាកូនរបស់ព្រះ វរបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌" (ម៉ាថាយ៥:៤៣-៤៥ក)។ ដូច្នេះ បញ្ហានៃទំនុកដាក់បណ្ដាសានាំ ឲ្យមានទំរង់សំនួរខាងសីលធម៌មួយ។ តើឲ្យអ្នកនោះស្រឡាញ់ និងអធិស្ឋានដល់ខ្មាំងសត្រូវរបស់ពួកគេក្នុង ពេលតែមួយដូចម្ដេចទៅ ដ្បិតសោកនាដកម្មនោះចង់នាំឲ្យគេចង់តយុទ្ធជាមួយអ្នកនោះភ្លាមៗ?

---

[1] Bullock C. Hassell, *Encountering the Book of Psalms*, (Grand Rapids: Baker Academic, 2001), 227-238.

ដើម្បីដាក់បញ្ហានេះនៅក្នុងទស្សនៈផ្សេងៗ ទំនុកដាក់បណ្តាសាបានដាក់ទាំងអ្នកនិពន្ធ និង ព្រះជាម្ចាស់ ទៅក្នុងបរិបទនៃសេចក្តីក្រោធ និងការសងសឹក។ តើកវីនេះជានរណា បានអធិស្ឋានសូមឲ្យកើតមានការអា ក្រក់លើខ្មាំងសត្រូវរបស់គាត់? តើព្រះជាម្ចាស់ទ្រង់ជានរណា ដែលអ្នកនិពន្ធគិតថា ទ្រង់គង់នៅជាមួយនឹងគាត់ ហើយព្រមធ្វើការអាក្រក់បែបដូច្នោះ?

**ដំណោះស្រាយ**

**លក្ខណៈរបស់អ្នកកវីនិពន្ធ**

មានពួកអ្នកប្រាជ្ញមួយចំនួនស្វែងរកនូវដំណោះស្រាយ ឬយ៉ាងហោចណាស់ជាដំណោះស្រាយដែលមិនទាន់ពេញលេញ ចំពោះបញ្ហានៃទំនុកនេះ នៅក្នុងលក្ខណៈរបស់អ្នកកវីនិពន្ធ។ ដ្បិតអ្នកកវីនិពន្ធមានចេតនា ប្រើប្រាស់សម្តីបំភ្លើស និងតាមរយៈលក្ខណៈការសង្កត់ធ្ងន់ពីរូបភាពនោះឲ្យកាន់តែច្បាស់ និងខ្លីគោលបំណង របស់ម្ចាស់នៃការពន្យល់នេះចង់បង្ហាញថា បញ្ហានឹងត្រូវបានដោះស្រាយដោយអ្នកកវីនិពន្ធផ្ទាល់។ លោក Erich Zenger រកឃើញថា ដំណោះស្រាយនេះមានភាពលំអៀង ព្រោះលក្ខណៈទទូចរបស់កវីនិពន្ធទំនុកដាក់បណ្តាសាបានឆ្លើយតបថា ពួកគេបានវាយតម្លៃខ្ពស់ហួសលើស្ថានភាព។ ស្ថិតនៅក្រោមការដាក់បញ្ចូលក្នុង ស្ថានភាពកន្លែងនេះ គឺបង្ហាញថា ចំនុចដែលមាននៅក្នុងការដាក់បណ្តាសារក្នុងទំនុកនេះ គឺសម្រាប់តែខាងព្រលឹងវិញ្ញាណ ឬ ការប្រៀបធៀបតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ យើងត្រូវតែទទួលយកថា ការនិពន្ធនេះគឺជាអ្នកបង្ហាញពីសេចក្តីក្រោធ ដែលពួកគេចង់ឲ្យមនុស្សឯទៀតជួបសេចក្តីអន្តរាយ សេចក្តីអាម៉ាស់ហើយអាចឈានដល់ស្លាប់បាន។

**ប្រសិទ្ធភាពនៃមន្តអាគម**

លោក Sigmund Mowinkel បានស្នើរថា ទំនុកនេះត្រូវបានកាត់ចេញពីការកំណត់របស់លោកិយដែលពួកអាបធ្មប់ជាផ្នែកមួយនៃសាសនា បានអនុវត្ត។ គាត់បានគិតថា ទំនុកដាក់បណ្តាសា គឺជាឧទាហរណ៍មួយ "ប្រសិទ្ធភាព" នៃមន្តអាគម តាមរយៈ "ការដាក់បណ្តាសា" លើខ្មាំងសត្រូវ ដែលអ្នកនិពន្ធទំនុកដំកើងនោះបានដាក់បណ្តាសា ហើយរំពឹងថា ការអាក្រក់ទាំងនោះនឹងធ្លាក់លើពួកគេ។ យ៉ាងណាមិញ នៅក្នុងសញ្ញាចាស់ ហាក់បីដូចជាមិនបង្រៀនឲ្យមានការអនុវត្តបែបទំលាប់របស់អ្នកមិនជឿព្រះក្នុងការដាក់បណ្តាសាទាល់តែសោះ។ លោក Keel មានប្រសាសន៍ថា "រឿងមន្តអាគម គឺជារឿង ដែលហាមឃាត់ចំពោះពួកអ៊ីស្រាអែលនៅក្នុងការទាស់ប្រឆាំងនឹងពួកខ្មាំងសត្រូវរបស់គាត់។ ដូច្នេះគាត់ត្រូវបែរ មករកព្រះយេហូវ៉ាដោយផ្ទេរបន្ទុកទាំងមូលរបស់គាត់ទៅកាន់ព្រះ នៅពេលដែលគាត់ត្រូវការជំនួយ"។ លើសពីនេះទៅទៀត បើតាមមើលទៅ សារៈសំខាន់នៃទំនុកដំកើង ហាក់ដូចជាមិនលាក់លាមទេ បើសិនជាអ្នកចងក្រងបានដឹងពីការនេះ។

**ភាពអន់ថយខាងសីលធម៌**

ជួនកាលអ្នកកាត់ស្រាយកណ្ឌទំនុកដំកើងពឹងផ្អែកការពន្យល់ ដែលដាក់ទំនុកដំកើងប្រភេទដាក់បណ្តាសានៅក្រោមចំណងជើងនៃសីលធម៌គម្ពីរសញ្ញាចាស់ហើយគូសបង្ហាញពីភាពផ្ទុយគ្នានឹងសីលធម៌

នៅសញ្ញាថ្មីរបស់ព្រះយេស៊ូវ ដែលយើងត្រូវស្រឡាញ់ដល់ខ្មាំងសត្រូវរបស់យើងនោះ (ម៉ាថាយ ៥:៤៣-៤៥)។ ចំពោះទស្សនៈនេះជួនកាល តំណាងឲ្យការពន្យល់ពីការសេចក្តីសញ្ញាចាស់/សេចក្តីសញ្ញាថ្មី។

គឺជាការពិតដែលគោលការណ៍សីលធម៌នៅក្នុងសញ្ញាចាស់ដាក់ដំបូលដោយសីលធម៌នៃសេចក្តីស្រឡាញ់(ចោទិ ៦:៤) និងសរសរជើងក្រោមដោយការសងសឹក (ចោទិ.១៩:២១)។ គេរកឃើញដំបូលនៃសីលធម៌នៃសញ្ញាចាស់នៅក្នុងសេចក្តីបង្គាប់ឲ្យស្រឡាញ់ព្រះជាម្ចាស់(ចោទិ.៦:៤) និងស្រឡាញ់អ្នកជិតខាងឲ្យដូចជាខ្លួនឯង (លេវី.១៩:១៨)។ តាមពិត គ្មានសីលធម៌ណាដែលខ្ពស់ជាង ស្រឡាញ់ព្រះជាម្ចាស់ឲ្យអស់ពីចិត្ត និងស្រឡាញ់អ្នកជិតខាងដូចជា ខ្លួនឯងនោះទេ។ ព្រះយេស៊ូវទ្រង់បានចាត់ទុកសេចក្តីបង្គាប់ពីរនេះបញ្ញតិធំបំផុត(ម៉ាថាយ២២:៣៦-៤០)។ ទោះបីជាសញ្ញាចាស់មិនដែលតាក់តែងក្រិត្យវិន័យនៃសេចក្តីស្រឡាញ់ដូចជាព្រះយេស៊ូវក៏ដោយ ក៏ក្រិត្យវិន័យនៃសេចក្តីស្រឡាញ់បានតម្រូវឲ្យអ៊ីស្រាអែលប្រព្រឹត្តចំពោះពួកខ្មាំងសត្រូវរបស់ពួកគេដោយយុត្តិធម៌និងដោយការចេះគិតពិចារណាចង់ឲ្យគេប្រព្រឹត្តនឹងខ្លួនវិញ "បើប្រទះឃើញគោ ឬលា របស់ខ្មាំងសត្រូវ ដែលវង្វេង នោះត្រូវឲ្យនាំទៅ ប្រគល់ដល់ ម្ចាស់វិញជាកុំខាន បើឃើញលារបស់អ្នកណាដែលស្អប់ឯង វាលុតជង្គង់ចុះដោយសារបន្ទុកធ្ងន់ នោះប្រហែល ជាឯងនឹងចង់ធ្វើព្រងើយតតជួយគេទេ តែមិនត្រូវធ្វើដូច្នោះឡើយ គឺត្រូវជួយដល់គេវិញជាកុំ ខាន" (និក្ខ.២៣:៤-៥)។

នៅជិតខាងចុងសីលធម៌នៃសញ្ញាចាស់គឺជាការអនុវត្តន៍ក្រិត្យវិន័យសងសឹកក្នុងលក្ខណៈស្មើគ្នា។ ខណៈដែលមិនមែនមិនមានតម្លៃទាំងស្រុងនៃសីលធម៌ដែលត្រូវបានគេគ្រោងក្នុងក្រិត្យវិន័យនៃសេចក្តីស្រឡាញ់ តែមិនបានទៅដល់កម្រិតនៃសីលធម៌ដែលព្រះយេស៊ូវបានបង្រៀននៅក្នុងសេចក្តីបង្រៀននៅលើភ្នំ។ គម្ពីរចោទិយកថាសង្ខេបផ្នែកនេះក្នុងករណីនៃម្នាក់ដែលធ្វើស្មបន្ទាល់ក្លែងក្លាយទាស់នឹងជនរួមជាតិអ៊ីស្រាអែល។

បើកាលណាមានស្មរបន្ទាល់ក្លែងក្លាយ ឈរឡើងធ្វើបន្ទាល់ទាស់នឹងមនុស្សណា ពីបទឧក្រិដអ្វី មួយ ត្រូវនាំអ្នកដែលទាស់ទែងគ្នា ឈរនៅចំពោះព្រះយេហូវ៉ា ត្រង់មុខពួកសង្ឃ នឹងចៅក្រម ដែលទទួល តួនាទីនៅពេលនោះ ។ ពួកចៅក្រមត្រូវស៊ើបអង្កេតដោយហ្មត់ចត់ បើឃើញថា អ្នកនោះជាស្មរបន្ទាល់ក្លែងក្លាយមែន ហើយបានធ្វើបន្ទាល់ក្លែងក្លាយទាស់នឹងបងប្អូន នោះត្រូវឲ្យឯងរាល់គ្នាប្រព្រឹត្តនឹងអ្នកនោះ ដូចជា អ្នកនោះបានគិតធ្វើដល់បងប្អូនវិញ យ៉ាងនោះឯងនឹងបំបាត់សេចក្តីអាក្រក់ពីពួកឯងចេញ ដូច្នេះអ្នកឯងទៀត នឹងឮ ហើយកោតខ្លាចរួចនឹងលែងប្រព្រឹត្តការអាក្រក់យ៉ាងដូច្នោះ នៅក្នុងពួកឯងតទៅ មិនត្រូវឲ្យភ្នែកឯងប្រណីគេឲ្យសោះ ត្រូវធ្វើឲ្យជីវិតធួននឹងជីវិត ធ្មេញធួននឹងធ្មេញ ដៃធួននឹងដៃ ជើងធួននឹងជើងវិញ (ចោទិ.១៩:១៦-២១)។

ខណៈដែលក្នុងបរិបទគម្ពីរសញ្ញាចាស់ ក្រិត្យវិន័យនេះបានអះអាងថា មនុស្សត្រូវតែទទួលខុសត្រូវចំពោះការប្រព្រឹត្តរបស់ខ្លួន ហើយអ្នកនោះត្រូវទទួលវិញតាមដែលខ្លួនបានប្រព្រឹត្ត តែក្នុងសីលធម៌ដែលព្រះយេស៊ូវបង្រៀនវិញ យើងប្រហែលជាពិបាកដោយរំពឹងថា គេត្រូវបែរថ្ពាល់ម្ខាងទៀតនោះទេ ។ វាមិនពិបាកយល់សោះឡើយ តើហេតុអ្វី បានជាគោលការណ៍នៃកិរិយាប្រព្រឹត្តនេះ ទាស់នឹងវិញ្ញាណព្រះយេស៊ូវ។

លោក John L. KcKenzie បានដាស់តឿនយ៉ាងប្រុងប្រយ័ត្នថា យើងត្រូវតែប្រុងប្រយ័ត្ន មិនត្រូវអានប្រព័ន្ធសីលធម៌ដែលទាស់គ្នាពីសញ្ញាចាស់និងសញ្ញាថ្មីទេ។ តាមពិត ព្រះយេស៊ូវទ្រង់បានបង្រៀន ថា ក្រិត្យវិន័យអំពីការលែងលះ គឺដោយសារតែចិត្តមនុស្សរឹងរបឹងប៉ុណ្ណោះ តែកាលពីដើមដំបូងបង្អស់នៃការបង្កើតរបស់ព្រះ មិនអញ្ចឹងឡើយ ទ្រង់បានបង្កើតស្តង់ដាខ្ពស់ណាស់(ម៉ាថាយ ១៩:៨)។

ករណីសាកល្បងគឺ ឲ្យពួកអ៊ីស្រាអែលបំផ្លាញពួកកាណានទាំងស្រុងកុំឲ្យសល់នៅ ជាសេចក្តីបង្គាប់ផ្ទាល់មកពីព្រះជាម្ចាស់ តែពួកគេមិនដែលធ្វើតាមបានទាំងស្រុងទេ។ អ្នកនិពន្ធកណ្ឌគម្ពីរចៅហ្វាយផ្ទាល់មិនងាយស្រួលទេចំពោះមុខតំណែងនេះ ដូចជាបានបង្ហាញច្បាស់ចេញពីការពន្យល់ក្នុង(ចៅហ្វាយ២:២២ខ-២៣)៖

"ដោយព្រោះសាសន៍នេះបានរំលងសេចក្តីសញ្ញា ដែលអញបានតាំងនឹងពួកឰយុកោគេ ហើយមិនបានស្តាប់តាមពាក្យរបស់អញ បានជាពីនេះទៅមុខ អញលែងបណ្តេញសាសន៍ណាមួយ ដែលយ៉ូស្វេបានទុកពីកាលស្លាប់ទៅនោះ ចេញពីមុខគេឡើយ ដើម្បីឲ្យអញបានល្បងលអ៊ីស្រាអែលមើល បើគេនឹងខំប្រឹងដើរតាមផ្លូវរបស់ព្រះយេហូវ៉ា ដូចជាពួកឰយុកោគេបានកាន់តាមឬទេ ដូច្នេះព្រះយេហូវ៉ាទ្រង់បានទុកសាសន៍ទាំងនោះវិញ ឥតបណ្តេញទៅយ៉ាងរហ័សទេ ក៏មិនបានប្រគល់មកក្នុងកណ្តាប់ដៃយ៉ូស្វេដែរ"

ហេតុផលនៅពីក្រោយការបំផ្លាញពួកកាណានចេញ គឺថា ពួកគេបានធ្វើឲ្យសីលធម៌របស់ពួកអ៊ីស្រាអែលធ្លាក់ចុះក្នុងសេចក្តីលាមកអាក្រក់ ពុករលួយថ្វាយបង្គំរូបព្រះរបស់ពួកកាណាន។ ការពន្យល់នេះគ្រប់គ្រាន់សម្រាប់ពួកអ៊ីស្រាអែលនៅសញ្ញាចាស់ ប៉ុន្តែវានៅមានបញ្ហាសម្រាប់យើងរស់នៅក្នុងបរិបទសញ្ញាថ្មី។ តែមុនពេលយើងថ្កោលទោសភ្លាមៗ យើងគួរតែឆ្ងល់ថា តើលោកីយ៍នេះនឹងទៅជាយ៉ាងណា ប្រសិនបើពួកអ៊ីស្រាអែលបានផ្លាស់ប្តូរសេចក្តីជំនឿរបស់ពួកគេទៅជឿលើព្រះរបស់ពួកកាណានវិញ។ តើសេចក្តីចុងបញ្ចប់នឹងផ្តល់ហេតុផលល្អទៅអត្ថន័យយ៉ាងណា? វាគឺជាសំនួរមួយដ៏ពិបាកនៅក្នុងករណីនេះ យើងត្រូវតែដោះស្រាយតាមស្ថានភាពពិតដែលយើងដឹង។ នៅក្នុងព្រឹត្តិការណ៍នីមួយៗ ការពន្យល់ពីសីលធម៌ដែលខ្ពស់ជាងទាស់នឹងសីលធម៌ដែលទាបជាងបានបំផ្លើសភាពខុសគ្នានៃសីលធម៌ក្នុង សញ្ញាចាស់និងសញ្ញាថ្មី ហើយបង្កើតឲ្យមានការបែងចែកខ្ពស់ និងទាប។ ភាពខុសគ្នាខាងសីលធម៌ បាន បង្ហាញច្បាស់ ហើយពួកជំនុំក៏បានទទួលស្គាល់ដែរ តែភាពខុសគ្នាទាំងនោះជាភាពខុសគ្នានៃកម្រិតច្រើនជាងប្រភេទ។

**ទំនាយពីសេចក្តីជំនុំជម្រះ**

ដោយព្រោះតែភាពមិនសុខស្រួលរបស់យើងចំពោះទំនុកតំកើងបណ្តាសា នោះយើងមានសេចក្តីល្បួង ឲ្យលើកទំនុកតំកើងទាំងនោះឲ្យខ្ពស់ជាងស្ថានភាពប្រវត្តិសាស្ត្រនិងស្ថានភាពផ្ទាល់របស់ទំនុកតំកើងទាំងនោះ ហើយឲ្យទំនុកតំកើងទាំងនោះថ្លែង តាមបែបជាក្រុម ជាជាងនិយាយចំៗ។ ការមួយដែលបង្កើតឲ្យមានសេចក្តីល្បួង គឺចេញមកពីការកាត់ស្រាយទំនុកដំកើងនេះ គឺជា ទំនាយពីថ្ងៃជំនុំជំរះនៅអនាគតលើមនុស្សអាក្រក់ ជាជាងការកាត់ស្រាយថាជាសេចក្តីអធិស្ឋានរបស់បុគ្គលចំពោះសេចក្តីជំនុំជម្រះ ពីការហិន

វិនាសទៅលើពួកគេ។ ជាការពិតដែលទំនុកខ្លះសំដៅទៅព្រះយេស៊ូវនៅសញ្ញាថ្មី តែលក្ខណៈដើមនិងស្ថានភាពប្រវត្តិសាស្ត្រដែលអ្នកនិពន្ធទំនុកតំកើងថ្លែង ជាហេតុផលដែលទាស់នឹងសេចក្តីល្បួងនេះ។

តាមពិតទៅ ប្រសិនបើយើងយកទំនុកតំកើងទាំងនេះចេញពីបរិបទប្រវត្តិសាស្ត្រ គឺ ដកយកការអនុវត្តន៍ដ៏មានអំណាចទៅចំពោះការរងទុក្ខនិងការសុគតរបស់ព្រះយេស៊ូវ ហើយដកយើងចេញពីអត្តសញ្ញាណជាមួយទ្រង់ និងទ្រង់ជាមួយយើង។

មិនអាចបដិសេធបានទេថា ទំនុកតំកើងបណ្តាសាពណ៌នាពីផលនៃការប្រព្រឹត្តអាក្រក់ ដែលទំនុកតំកើងទាំងនោះមានលក្ខណៈជាការបង្រៀន។ តែមិនបដិសេធចោលលក្ខណៈផ្ទាល់នៃសេចក្តីអធិស្ឋានទាំងនេះបានឡើយ។ ប្រសិនបើភ្ជាប់ការប្រព្រឹត្តអាក្រក់ទៅនឹង សេចក្តី វិនាស ដែលអ្នកនិពន្ធ បានបង្រៀនយើងឲ្យឃើញពីលទ្ធផលនៃការប្រព្រឹត្តរបស់បុគ្គល នោះជាអនុផលដែលគេស្វាគមន៍ តែពិបាកឲ្យចាត់ទុកថាជាគោលបំណងគ្រឹះរបស់អ្នកអ្នកនិពន្ធដើមបានឡើយ។ ។

**នៃព្រះមេស្ស៊ី**

កត្តាដែលអ្នកនិពន្ធសញ្ញាថ្មីជាច្រើនបានដកស្រង់ចេញពីទំនុកទាំងនេះ នៅក្នុងឱកាសផ្សេងៗជាវិភាគទានជួយដល់ទស្សនៈដែលទំនុកតំកើងបណ្តាសា ឲ្យគេមើលឃើញជាប្រភេទនៃព្រះមេស្ស៊ី ។ ព្រះយេស៊ូវទ្រង់ បានដក ស្រង់ពីទំនុក ៣៥:១៩/៦៩:៤ ដើម្បីពន្យល់ថា លោកីយ៍នេះបានស្អប់ដល់ទ្រង់ (យ៉ូហាន១៥:២៥)។ ហើយ ពួកសិស្សទ្រង់បានចងចាំទំនុក៦៩:៩ ដើម្បីដាក់នូវការលាងសំអាតព្រះវិហារចូលទៅក្នុងបរិបទនៃបទគម្ពីរនោះ (យ៉ូហាន២:១៧)។ លោកប៉ុលក៏ធ្លាប់បានឮពីទំនុក ៦៩:៩ និយាយអំពីព្រះគ្រីស្ទ និងការរងទ្រង់របស់ទ្រង់ (រ៉ូម១៥:៣) ទំនុក ៦៩:២២-២៣ បានទាយទុកពីភាពខ្វាក់របស់ពួកយូដាមើលមិនឃើញបេសកកម្មនៃព្រះមេស៊ីរបស់ព្រះគ្រីស្ទ (រ៉ូម១១:៩-១០)។ ជាងនេះទៅទៀត ចំពោះហេតុការណ៍ដែលយូដាសស្លាប់ តើអ្នកណានឹងមកជំ នួសកន្លែងគាត់ លោកពេត្រុសបានណែនាំឲ្យគេទទួលយកម៉ាត់ធាស ជំនួសយូដាវិញ ក្នុងទំនុក៦៩:២៥ និង១០៩:៨ (កិច្ចការ១:២០)។ តែការដកស្រង់ទាំងនេះត្រូវបានជ្រើសរើស ហើយហាក់បីដូចជាគ្មានហេតុផលណាដែលគិតថា ពួកសាវកបានមើលទំនុកទាំងនេះថាបែបនៃព្រះមេស្ស៊ីទាំងស្រុងឡើយ។

**ការចងគំនុំរបស់មនុស្សលើសេចក្តីបង្គាប់របស់ព្រះជាម្ចាស់**

មានអ្នកខ្លះបានសរសេរថាទំនុកតំកើងបណ្តាសាចេញក្រៅពីបញ្ជីរដែលព្រះបណ្តាលឲ្យតែង។ ពួកគេបានចចេសថា អ្នកនិពន្ធទំនុកដំកើងគឺកំពុងបង្ហាញពីការចងគំនុំរបស់ពួកគេទៅលើពួកខ្មាំងសត្រូវរបស់ពួកគេ ហើយព្រះជាម្ចាស់ទ្រង់មិនបានធ្វើអ្វីចំពោះការបណ្តាលឲ្យតែងក្នុងពាក្យរបស់ពួកគេនោះទេ។ ខណៈដែលជាការត្រឹមត្រូវដែរ ដែលថាព្រះគម្ពីរមានផ្ទុកនូវពាក្យស្អប់ជាច្រើន ដែលមិនសំដៅផ្ទាល់ទៅនឹងសេចក្តីពិតរបស់ព្រះ ឡើយ (ឧទាហរណ៍ ការចោទប្រកាន់យ៉ាងខ្លាំងរបស់លោកយ៉ូបទាស់នឹងព្រះជាម្ចាស់) ។ តាមរយៈបរិបទ នៃពាក្យទាំងនោះ ដែលផ្តល់នូវទស្សនៈថា ពាក្យទាំងនោះគឺជាព្រះបន្ទូលរបស់ព្រះ។ ខណៈ

ដែលព្រះ ជាម្ចាស់ទ្រង់មិនបានបណ្ដាលនូវពាក្យមួយចំនួនរបស់យ៉ូប ដែលពាក្យទាំងនោះសម្ដែងពីព្រះហឫទ័យរបស់ព្រះតាមរបៀបមួយដែល  ទ្រង់បានដាក់គាត់នៅក្នុងការបែបនោះ ដោយស្គាល់ថាលោកយ៉ូបមានលក្ខណៈបែបណា ហើយគាត់អាចនឹងឆ្លើយ តបនៅក្នុងរបៀបណាមួយបាន ហើយគាត់អាចនិយាយការពិតអំពីព្រះ  អាចជាសេចក្ដីពិត និងជាសេចក្ដីមិន ពិត។ ដូច្នេះ សេចក្ដីសរុបនៃសាច់រឿង និងកិច្ចសន្ទនាគឺដោយព្រះបន្ទូលរបស់ព្រះ ដែលបង្កើតបានជាសារនៃព្រះបន្ទូលពីព្រះហឫទ័យរបស់ព្រះ និងនិងស្ថានភាពពីបាកសម្រេចចិត្តរបស់មនុស្ស។ ហេតុនេះនេះ នៅតែសមរម្យ តាមពិតជាពាក្យបង្គាប់  ឧទាហរណ៍ នៅពេលយើងអានយ៉ូប១៦:១១-១៤ យើងណែនាំថាអត្ថបទនេះថា "ចូរស្ដាប់ព្រះបន្ទូលរបស់ ព្រះយេហូវ៉ា"។

ប្រហែលជាយើងអាចទទួលស្គាល់បានថា ពាក្យមួយចំនួននៅក្នុងទំនុកដំកើងទាំងនេះ មិនសមរម្យនៅក្នុងបបូរមាត់របស់ពួកអ្នកជឿឡើយ (ទំនុក១៣៧.៨) ប៉ុន្តែសារនៃសេចក្ដីយុត្តិធម៌របស់ព្រះ គឺជាសេចក្ដីសម្ដែងពីពីចរិតលក្ខណៈរបស់ទ្រង់មានភាពច្បាស់លាស់ និងសណ្ដាប់ធ្នាប់។ ចំពោះខ្លួនយើងផ្ទាល់ មិនគួរនិយាយចេញនូវការទាំងនោះទេ ទោះបីជាយើងមានទំនុកចិត្តថា យើងអាចថ្វាយទៅព្រះដើម្បីរកយុត្តិធម៌ក៏ដោយ។ យ៉ាងណាមិញ ព្រះជាម្ចាស់ទ្រង់មានបន្ទូលតាមរយៈអ្នកនិពន្ធទំនុកដំកើង ដោយការផ្ដល់នូវទស្សនៈគំនិតដែលលើកឡើងពីសេចក្ដីត្រូវការចង់បានយុត្តិធម៌របស់មនុស្សនិងសេចក្ដីប្ដូរផ្ដាច់របស់ព្រះជាម្ចាស់ក្នុងការនោះ។ នៅក្នុងការពិភាក្សាពីទុំនុកតំកើងបណ្ដាសាទាំងនេះ យើងគួរតែព្យាយាមពន្យល់វែកញែកនូវទស្សនៈនេះ។

### សេចក្ដីតំណាងពីភាពអយុត្តិធម៌របស់មនុស្ស

តួនាទីនេះបាននាំឲ្យគិតពីស្ថានភាពប្រវត្តិសាស្ត្រហ្មត់ចត់ដែរ ដោយយល់ថាទំនុកទាំងនេះត្រូវបានសរសេរដោយបុគ្គលដែលបានរងទុក្ខដោយអយុត្តិធម៌។ ប៉ុន្តែការនោះមិនឈប់ត្រឹមនោះទេ។ បុគ្គលទាំងនេះតំណាងឲ្យមនុស្សនៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែងដែលបានរងទុក្ខដោយភាពអយុត្តិធម៌។ សមាសធាតុតំណាងនាំការកាត់ស្រាយនេះមានគោលបំណងដាក់ទំនុកតំកើងបណ្ដាសារនេះឲ្យមានគុណភាពអាចបញ្ចូលទៅក្នុងព្រះគម្ពីរបរិសុទ្ធ។ កត្តាដែលសម្លេងពីបុរាណទាំងនេះថ្លែងតំណាងនៃបុគ្គលដែល បំពាននៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា បើតាមការប៉ាន់ស្មាន លើកខ្ពស់ជាងការចោទសួរខាងសីលធម៌ ទៅទៀត។ ខណៈដែលមានសេចក្ដីលំអៀងទៅទស្សនៈនោះ នៅតែមិនធ្វើឲ្យថយចុះការបារម្ភពី"បណ្ដាសា" ដែលអ្នកនិពន្ធអធិស្ឋានសូមឲ្យការនោះធ្លាក់ទៅពួកខ្មាំងសត្រូវរបស់ពួកគេ ហើយជាការពិត គេមិនអាចគេចចេញពីបញ្ហាដែលទំនុកតំកើងបណ្ដាសារបានចោទសួរក្នុងទស្សនៈសីលធម៌របស់ព្រះយេស៊ូវឡើយ។ ពេលដែលមាននរណាម្នាក់បានប្រព្រឹត្តខុសឆ្គងចំពោះយើង ព្រះយេស៊ូវបានបង្រៀនឲ្យអ្នករងគ្រោះ ស្រឡាញ់ និងអធិស្ឋានដល់អ្នកដែលបានប្រព្រឹត្តខុសឆ្គង។

### ពាក្យសម្ដីនៃអ្នកផ្សេងៗទៀត

ទស្សនៈនៃកំណាព្យទាំងនេះ ដោយមានគោលបំណងល្អក្នុងការចៀសពីបញ្ហា។ ក្នុងលក្ខណៈក្លែងការពិត អ្នកកាត់ស្រាយទាំងនេះព្យាយាមដាក់ពាក្យសាហាវបំផុតទៅកាន់បុគ្គលផ្សេងៗជាជាង ថាវាជាពាក្យរបស់អ្នកនិពន្ធទំនុកដំកើងបានសរសេរឡើង។ ខណៈដែលពួកគេចាប់អារម្មណ៍ក្នុងការ "ការពារ" សេចក្ដីសុចរិតត្រឹមត្រូវខាងទេវសាស្ត្រនៃទំនុកតំកើង ហើយពួកគេច្រានចោលសេចក្ដីពិតខាងប្រវត្តិសាស្ត្រនៃកំណាព្យទាំងនេះ។ អ្នកកាត់ស្រាយយល់ថា ទំនុកដាក់បណ្ដាសានេះគឺមិនពិតនោះទេ ហើយមិនអាចយកអនុវត្តនៅក្នុងជីវិតដូចគ្នា សេចក្ដីខុសឆ្គងនៃទស្សនៈកាត់ស្រាយទាំងនេះមាន បានយល់ថា ទំនុកនេះមិនអាចយកទៅអនុវត្តនៅក្នុងជីវិតទេ។ ហើយមានអ្នកប្រាជ្ញព្រះគម្ពីរតិចតួចណាស់ ដែលយល់ស្រមចំពោះការនេះ។

### ជាតិជាជាងបុគ្គល

អ្នកផ្សេងទៀត ក្នុងគោលបំណងរក្សាព្រះគម្ពីរបរិសុទ្ធឲ្យខ្ពស់ជាងសេចក្ដីសង្ស័យខាងសីលធម៌ទាំងឡាយ បានអនុវត្ត"បណ្ដាសា"ទាំងនេះទៅចំពោះប្រជាជាតិនានា ជាជាងអនុវត្តទៅបុគ្គលម្នាក់ៗ។ មុនដំបូង ការនេះហាក់បីដូចជាគំនិតដ៏ ល្អណាស់។ យ៉ាងហោចណាស់ វាចៀសវាងនូវការស្អប់ខ្ពើមផ្ទាល់ខ្លួនដែលទំនុកតំកើងបណ្ដាសាសម្ដែងទៅកាន់បុគ្គលម្នាក់ៗ ជាងទៅកម្រិតជាតិ។ វាគឺជាការពិត នៅក្នុងស្ថានភាពមួយចំ នួន ដូចជាទំនុក៧៩ និង៨៣ អ្នកនិពន្ធបាននិយាយអំពីពួកខ្មាំងសត្រូវរបស់ប្រជាជាតិ ប៉ុន្តែការនេះមិនអាចនិយាយថាទំនុកតំកើងបណ្ដាសាទាំងអស់សុទ្ធតែដូចនោះទេ។ តាមពិតទៅគឺមានភាគច្រើន។ តែទំនុក៦៩ និង១០៩ បាននិយាយចំៗអំពីខ្មាំងសត្រូវរបស់បុគ្គល។ យ៉ាងណាមិញ លោក McKenzie បានតស៊ូយ៉ាងត្រឹមត្រូវ ចំពោះការប្រព្រឹត្តរបស់បុគ្គលគឺមានគោលការណ៍ខុសៗគ្នាពីសីលធម៌ថ្នាក់ជាតិនិងមិនបានប្រកាន់ខ្ជាប់ជារហូតទេ។

### ភាពខុសប្លែករវាងអំពើបាប និងមនុស្សមានបាប

នេះគឺជារឿងធម្មតា ហើយជារបៀបមួយដ៏សុចរិតនៃការដោះស្រាយចំពោះអំពើបាប និងមនុស្សមានបាប ក៏ស្ថិតនៅក្នុងចំណោមរបៀបដែលអ្នកកាត់ស្រាយបានដោះស្រាយជាមួយទំនុកតំកើង ទាំងនេះ។ លោក McKenzie បានប្រកាន់យកតួនាទីនេះ ហើយនិយាយថា "ឥឡូវនេះ ការស្អប់ខ្ពើមរបស់អ្នកនិពន្ធទំនុកតំកើង គឺប្រាកដជាបានតំរង់ទៅទាស់នឹងគុណភាពនៃការស្អប់៖ អំពើបាប" គាត់បានដាក់គ្រោងកំណត់ដើម្បីការពារ មនុស្សមានបាបទាស់នឹងសេចក្ដីស្អប់អំពើបាបរបស់អ្នកនិពន្ធ៖

1. ការស្អប់មិនត្រូវសំដៅទៅលើមនុស្សមានបាបទេ តែត្រូវសំដៅទៅអំពើបាបវិញ។
2. ទាំងអ្នកនិពន្ធទំនុកតំកើង ឬពួកអ្នកជឿឯទៀតៗប្រហែលចង់បាន សេចក្ដីយុត្តិធម៌ពីព្រះជាម្ចាស់ទាស់នឹងមនុស្សមានបាប ប៉ុន្តែគួរតែជាយុត្តិធម៌របស់ព្រះជាម្ចាស់ មិនមែនជាការសងសឹករបស់អ្នកនិពន្ធឡើយ។

3. ត្រូវតែទុកឱកាសឲ្យ បើមានការប្រែចិត្ត និងនៅពេលដែលគេមានចិត្តចង់បានភាពយុត្តិធម៌របស់ព្រះ ដើម្បីភាពចុះចាញ់។
4. ត្រូវតែមានសេចក្ដីស្រឡាញ់សម្រាប់មនុស្សមានបាបនៅជាមួយយើង៖ "មានពាក្យមួយថា មនុស្សមានបាបប្រហែលត្រូវគេស្អប់តាមច្បាប់តែពេលណាដែលគាត់ត្រូវគេស្រឡាញ់តែប៉ុណ្ណោះ"

មានយោបល់ច្រើនត្រូវផ្ដល់ឲ្យចំពោះទស្សនៈមួយនេះ។ បញ្ហានោះគឺថា ជាការពិបាកណាស់នៅក្នុងការញែកសេចក្ដីស្អប់អំពើបាបចេញពីសេចក្ដីស្អប់មនុស្សមានបាប។ ហើយយើងត្រូវតែសួរ ខ្លួនឯងជានិច្ចថា "តើអ្វីទៅដែលខ្ញុំពិតជាស្អប់? យើងគ្រប់គ្នាសុទ្ធតែជាមនុស្សមានបាប ដែលភាន់ច្រឡំពីសេចក្ដីស្អប់ទាំងពីរ ហើយក៏មិនប្រាកដថាមួយណាបែកចេញ និងមួយណាចាប់ផ្ដើមនោះដែរ។ គឺមានតែពួកបរិសុទ្ធដ៏ពិតទេ ដែលអាចគ្រប់គ្រងការនេះឲ្យមានតុល្យភាពថ្លៃថ្លា ទោះបី យើងគ្រប់គ្នាប្រាថ្នាចង់បានគោលដៅដ៏ខ្ពង់ខ្ពស់ត្រដែតក៏ដោយ។

## ការកាត់ស្រាយទំនុកតំកើងបណ្ដាសាជាព្រះបន្ទូលព្រះ

នៅក្នុងផ្នែកនេះ ខ្ញុំចង់ធ្វើការពិភាក្សាបន្ថែមទៀតនូវទិដ្ឋភាពមួយចំនួនអំពីទំនុកតំកើងបណ្ដាសា ដើម្បីព្យាយាមយល់ពីភាពវិជ្ជមាន និងអវិជ្ជមាននៃទេវសាស្ត្ររបស់ទំនុកតំកើងទាំងនោះ។

### ទស្សនៈគំនិតខាងទេវសាស្ត្ររបស់អ្នកនិពន្ធ

យើងគួរតែកត់សំគាល់ភ្លាមៗនូវទស្សនៈគំនិតរបស់អ្នកនិពន្ធលើការធ្វើទុក្ខទោសពីសំណាក់អ្នកបៀតបៀនមកលើគាត់។ ពួកគេបានតបស្នងការល្អរបស់គាត់ដោយការអាក្រក់៖ "គេប្រព្រឹត្តការអាក្រក់ដល់ទូលបង្គំស្នងនឹងការល្អដើម្បីឲ្យព្រលឹងទូលបង្គំត្រូវនៅតែឯង" (៣៥:១២)។ ការឈឺចាប់របស់គាត់ កាន់តែអាក្រក់ដោយសារតែពួកអ្នកបៀតបៀនសុទ្ធតែជាមិត្តភ័ក្ត្ររបស់គាត់៖

> *មិនមែនជាខ្មាំងសត្រូវដែលបកកេរខ្ញុំ យ៉ាងនោះខ្ញុំនឹងធន់ទ្រាំបាន ក៏មិនមែនជាអ្នកស្អប់ខ្ញុំដែលលើកខ្លួនទាស់នឹងខ្ញុំ នោះខ្ញុំនឹងបានពួនខ្លួនឲ្យរួចពីគេ គឺជាអ្នកឯងវិញ ជាមនុស្សស្មើគ្នានឹងខ្ញុំ ជាភឿនហើយជាសំ ឡាញ់ស្និទ្ធស្នាលនឹងខ្ញុំ យើងបានធ្លាក់ប្រឹក្សាគ្នាយ៉ាងផ្អែមល្ហែម ក៏ដើរជាមួយគ្នានៅកណ្ដាលហ្វូងមនុស្សក្នុង ដំណាក់ព្រះ" (៥៥:១២-១៤)។*
> *គេជាសត្រូវស្នងនឹងសេចក្ដីស្រឡាញ់របស់ទូលបង្គំ ប៉ុន្តែទូលបង្គំផ្ចង់ចិត្តនឹង អធិស្ឋានវិញ គេបានសងការអាក្រក់ដល់ទូលបង្គំ ស្នងនឹងការល្អ ហើយស្នងសេចក្ដីសំអប់ ចំពោះសេចក្ដីស្រឡាញ់របស់ទូលបង្គំ (១០៩:៤-៥)។*

កត្ដានេះពិតជាបានដាក់អ្នកអធិស្ឋានទាំងនេះ នោក្នុងពន្លៃដ៏គួរឲ្យចាប់អារម្មណ៍ ដូចគ្នាយ៉ាងច្រើនជាមួយនឹងរឿងរបស់លោកយ៉ូប និងមិត្តរបស់គាត់ដែរ។

ការអង្កេតទីពីរគឺថា អ្នកនិពន្ធបានតយុទ្ធថា ខ្មាំងសត្រូវរបស់គាត់គ្មានហេតុផលណាប្រព្រឹត្ត ការអាក្រក់ទៅលើគាត់ឡើយៈ

*ដ្បិតមាត់របស់មនុស្សអាក្រក់ នឹងមាត់មាយា បានហាឡើងទាស់នឹងទូលបង្គំហើយ គេបាននិយាយនឹងទូលបង្គំ ដោយអណ្តាតកំភូត គេបានឡោមព័ទ្ធទូលបង្គំជុំវិញដោយពាក្យសំអប់ ក៏តយុទ្ធនឹងទូលបង្គំ ដោយ គេឥតហេតុ (១០៩:២-៣, ៣៥:៧, ១៩, ៥៩:៣-៥, ៦៩:៤)។*

ការអង្កេតទីបី គន្លឹះមួយជួយឲ្យយល់ពីអារម្មណ៍ និងអាកប្បកិរិយារបស់អ្នកនិពន្ធ ទេវសាស្រ្តរបស់គាត់ ប្រាកដជាមើលទៅលើទេវសាស្រ្តរបស់គាត់ គឺថា យ៉ាងហោចណាស់ក៏មានកឋាខ័ណ្ឌ១ គាត់នឹងទទួលស្គាល់ថា ការរងទុក្ខរបស់គាត់គឺព្រះអង្គទ្រង់ជាហេតុផលៈ

*ដ្បិតគឺដោយយល់ដល់ទ្រង់ហើយ បានជាទូលបង្គំធន់ទ្រាំនឹងសេចក្តីត្មះតិះដៀល ហើយសេចក្តីអៀនខ្មាសបានគ្របមុខទូលបង្គំផល ទូលបង្គំបានត្រឡប់ដូចជាអ្នកដទៃចំពោះបងប្អូនទូលបង្គំ គឺដូចជាសាសន៍ក្រៅ ដល់ពួកអ្នកពោះ១ នឹងទូលបង្គំ ដ្បិតសេចក្តីឧស្សាហ៍ដល់ដំណាក់ទ្រង់ បានស៊ីបង្ហិនទូលបង្គំ ឯសេចក្តីត្មះតិះ ដៀលទាំងប៉ុន្មានដែលគេដៀលដល់ទ្រង់ នោះបានធ្លាក់មកលើទូលបង្គំវិញ (៦៩:៧-៩)។*

នោះប្រាកដជាបានដាក់បញ្ហាទៅក្នុងទីតាំងនៃទេវសាស្រ្តដែលធំជាង ហើយហាក់បីដូចជាត្រូវបានពង្រឹងអ្នកនិពន្ធឲ្យទ្រាំទ្រចំពោះការបៀតបៀនដល់គាត់។

ទីបួន នៅខណៈដែលទំនុកចិត្តរបស់អ្នកនិពន្ធលើមនុស្សប្រុសស្រីបានថយចុះ សេចក្តីជំនឿរបស់គាត់លើព្រះនិងលើ សេចក្តីល្អរបស់ទ្រង់នៅតែដដែលៈ

*តែឱព្រះយេហូវ៉ា ជាព្រះអម្ចាស់អើយ សូមទ្រង់ប្រោសទូលបង្គំ ដោយយល់ដល់ព្រះនាមទ្រង់ សូមប្រោសឲ្យទូលបង្គំបានរួច ដោយព្រោះសេចក្តីសប្បុរសដ៏ប្រសើររបស់ទ្រង់ (១០៩:២១)។ ឱព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំអើយ សូមជួយទូលបង្គំផង ឱសូមជួយសង្គ្រោះទូលបង្គំតាមសេចក្តីសប្បុរនៃទ្រង់ (១០៩:២៦)។*

ទីប្រាំ អ្នកនិពន្ធគិតដល់សហគមន៍ដែលស្ថិតនៅក្រោមខ្សែបន្ទាត់នៃសុខមាលភាពខាងព្រលឹងវិញ្ញាណរបស់គាត់។ មានពួកអ្នកដែលបានដាក់សេចក្តីសង្ឃឹមលើការការពាររបស់ទ្រង់(៣៥:២៧) នឹងអស់អ្នកដែលបាន ទទួលឥទ្ធិពលអវិជ្ជមានតាមរយៈអ្វីដែលកើតឡើងចំពោះគាត់ៈ

*ឱព្រះយេហូវ៉ា ជាព្រះអម្ចាស់នៃពួកពលបរិវារអើយ សូមកុំឲ្យពួកអ្នកដែលពឹងពាក់ដល់ទ្រង់ត្រូវខ្មាស់ដោយព្រោះទូលបង្គំឡើយ ឱព្រះនៃសាសន៍អ៊ីស្រាអែលអើយ សូមកុំឲ្យពួកអ្នកដែលស្វែងរកទ្រង់បានត្រូវ អាប់យសដោយព្រោះទូលបង្គំឲ្យសោះ (៦៩:៦)។*

ខណៈដែលការអង្កេតទាំងនេះប្រហែលមិនអាចដោះស្រាយនូវបញ្ហានៃទំនុកតំកើងបណ្តាសាបាន តែទំនុកតំកើងទាំងនេះបានផ្តល់នូវបរិបទទេវសាស្ត្រខាងក្នុងឲ្យមើលឃើញពីបញ្ហា។ ទំនាក់ទំនងរបស់អ្នកនិពន្ធជាមួយព្រះគឺនៅលក្ខណៈល្អ មានសណ្តាប់ធ្នាប់ ហើយការប្រព្រឹត្តល្អរបស់គាត់ ចំពោះខ្មាំងសត្រូវបានឆ្លុះបញ្ចាំងពីការនោះ។ ទោះបីជាមានអ្វីកើតឡើងចំពោះរូបគាត់យ៉ាងណាក៏ដោយ កើតចេញពីលក្ខណៈនៃពួកអ្នកបៀតបៀនគាត់ ជាងលក្ខណៈ និងការប្រព្រឹត្តរបស់គាត់។ ជាងនេះទៅទៀត គាត់យល់ពីសេចក្តីរងទុក្ខរបស់គាត់ក្នុងន័យទូលំទូលាយ ហើយយកចិត្តទុកដាក់ពីរបៀបដែលសេចក្តីរងទុក្ខនោះជះឥទ្ធិពលដល់សហគមន៍ដែលគាត់រស់នៅ ។

**"បណ្តាសារ"**

ជាពាក្យដែលអ្នកនិពន្ធប្រើទាស់នឹងខ្មាំងសត្រូវរបស់គាត់ ពីសេចក្តីអធិស្ឋានថាឲ្យ ពួកគេបានស្រងាកចិត្តចំពោះការខំប្រឹងរបស់ពួកគេ ទៅសេចក្តីអធិស្ឋានថា ឲ្យពួកគេនិង កូនចៅប្រហែលត្រូវបំផ្លាញចុះ។ អ្នកនិពន្ធអធិស្ឋានយ៉ាងវែងដោយបញ្ជីរនៃ "បណ្តាសាជាច្រើន" ដល់ពួកខ្មាំងសត្រូវ ហាក់បីដូចជាគាត់មិនភ្លេចនូវគ្រោះណាមួយ ដែលគាត់បានជួបសោះឡើយ។

នៅពេលដែលគេមើលទៅលើលក្ខណៈ និងព្រំដែននៃ "បណ្តាសា" គឺជាគោលបំណងនៃអ្នកនិពន្ធបានសម្តែងច្បាស់ដែរ ទោះបីជាសេចក្តីជំរុញពីក្នុងចិត្តមិនបានសម្តែងចេញមកទាំងស្រុងក៏ដោយ។ តែ នៅក្នុងពន្លឺនៃភាពទាំងមូលនៃសេចក្តីអធិស្ឋានពីសេចក្តីជំនុំជម្រះទាំងនេះ អ្នកនិពន្ធមិនបានផ្តោតខ្លាំងទៅលើខ្លួនឲ្យដូចជាការដែលគាត់ផ្តោតទៅកាន់ព្រះជាម្ចាស់ទេ ក៏មើលងាយចំពោះខ្លួនឯងថា រូបរាងរបស់ខ្លួនធ្វើឲ្យរាំងស្ទះដល់និមិត្តនិងនគរព្រះ ហើយមិនពិនិត្យមើលផ្លូវចិត្តខាងក្នុងថា គាត់មិនអាចមើលឃើញផលប៉ះពាល់នៃការរងទុក្ខរបស់គាត់ដល់សហគមន៍របស់គាត់ដែរ។

**គោលការណ៍នៃសេចក្តីជំនុំជំរះ**

អ្នកនិពន្ធបានមើលឃើញពីគោលការណ៍ច្បាស់លាស់មួយចំនួនគ្រប់គ្រងពីរបៀបដែលសេចក្តីយុត្តិធម៌ត្រូវបានវាស់ស្ទង់។ ដំបូង គាត់រំពឹងថាព្រះអម្ចាស់ទ្រង់នឹងតយុទ្ធជាមួយនឹងអ្នកដែលបានធ្វើទុក្ខទោសដល់គាត់៖ *"ឱព្រះយេហូវ៉ាអើយ សូមទ្រង់ការពារទូលបង្គំចំពោះពួកអ្នកដែលតតាំងនឹងទូលបង្គំ សូមទ្រង់តស៊ូនឹងពួកអ្នក ដែលតស៊ូនឹងទូលបង្គំផង" (៣៥:១)*។ ប្រសិនបើយើងអាចរំពឹងកត់សំគាល់ ពីទេវសាស្ត្រដែលជាប់លាប់មិនផ្លាស់ប្តូរដ៏ជាក់លាក់ នៅក្នុងក្រុម ទំនុកតំកើងនេះ-ហើយខ្ញុំជឿថាយើង អាចនិយាយបានពីមូលហេតុរបស់គាត់ ដូចដែលយើងបានអង្កេតរួចមក ថាជាបុព្វហេតុរបស់ព្រះជាម្ចាស់ (៦៩:៧-៩)។ ដូច្នេះព្រះជាម្ចាស់ដ៏ជាព្រះនៃសេចក្តី យុត្តិធម៌ មិនអាចធ្វើអ្វីដែលតិចជាងដោះស្រាយ ជាមួយពួកខ្មាំងសត្រូវដែលទាស់នឹងអ្នកនិពន្ធ ហើយក៏ដូចជាព្រះជាម្ចាស់ផ្ទាល់ឡើយ។

**ទីពីរ** អ្នកនិពន្ធជឿ ឬយ៉ាងហោចណាស់បានអធិស្ឋានថា បំណងចិត្តនៃពួកមនុស្សអាក្រក់នឹងក្លាយជាសេចក្តីបំផ្លាញដល់ខ្លួន ៖ *"ហើយឲ្យអន្ទាក់ដែលគេបានលាក់នោះ ជាប់ខ្លួនគេវិញសូមឲ្យគេធ្លាក់ ទៅជាប់*

*អន្ទាក់នោះ ហើយវិនាសទៅផង" (៣៥:៨ខ,គ, ៥:១០,៧:១៥-១៦,៩:១៥)*។ គោលការណ៍នៃ **ការជំនុំជំរះ** មានសម្លេងដូចភាសិត (សុភាសិត២៦:២៧,២៨:១០) ហើយជាប់ទាក់ទងនឹងក្រិត្យវិន័យផ្នែក សីលធម៌ ថាចំណង់ចិត្តអាក្រក់នឹងបណ្តាលឲ្យមានផលផ្ទុយពីគោលបំណងរបស់ព្រះ ដែលព្រះទ្រង់បានបង្កើតផែនដី មក ហើយបានគ្រប់គ្រងលើសកម្មភាពរបស់មនុស្ស និងគ្រប់អ្វីៗ និងគ្រប់សកម្មភាពទាំង ឡាយក្លាយ ជាឧបករណ៍នៃបំណងព្រះហឫទ័យរបស់ទ្រង់។ តែទោះបីជាយ៉ាងណាក៏ដោយ ការនេះបានខូចបង់ទៅ ហើយ។ គោលការណ៍នេះ បានរកឃើញនៅក្នុងទំរង់អក្សរសាស្ត្រនៃគម្ពីរប្រាជ្ញា ក្នុងសណ្ឋាន ដើមត្រូវបាន បញ្ចេញសម្លេងនៅក្នុងឃ្លាពីបុរាណនៃទំនុកប្រាជ្ញានៃស្តេចសាឡូម៉ូន។ ដូចដែលអ្នកនិពន្ធ បានពណ៌ពីរបៀប ដែលព្រះជាម្ចាស់ទ្រង់បានប្រើភ្លើងបំផ្លាញពួកអេស៊ីបដែលដេញតាមពួកអ៊ីស្រាអែលយ៉ាងប្រកិត ហើយក៏ដូច ជាប្រើទឹកសមុទ្រគ្របលើពួកគេ (និក្ខមនំ១៤;២១-៣១) គាត់បានបង្កើតសណ្ឋាន ឃ្លាបុរាណនៃគោលការណ៍ នេះថា ៖ *"ភាគច្រើនចំពោះការដែលមិនគួរឲ្យជឿទាំងអស់ ដូចជាព្រះទ្រង់ប្រើទឹក សម្រាប់ បង្រ្កាបការទាំងអស់ ហើយភ្លើជាឥទ្ធិពលយ៉ាងអស្ចារ្យ សម្រាប់ការពារលោកីយ៍សុចរិត (ប្រាជ្ញាសាឡូម៉ូន១៦:១៧ NRSV, ខ២៤, ៥:២០)*។

| |
|---|
| **បណ្តាសា** |
| -បានទៅជាមានសេចក្តីខ្មាស ហើយអាប់យសទៅ (៣៥:៤ក,ខ២៦) |
| -បានត្រូវថយចេញដោយខ្មាសវិញ (៣៥:៤ខ) |
| -សូមឲ្យគេបានដូចជាចំបើងដែលខ្យល់ផាត់ទៅ ហើយឲ្យទេវតានៃព្រះយេហូវ៉ាដេញតាមគេផង (៣៥:៥) |
| -សូមឲ្យផ្លូវគេបានងងឹត ហើយរអិលព្រមទាំងមានទេវតានៃព្រះយេហូវ៉ាដេញតាមគេដែរ (៣៥:៦) |
| -សូមឲ្យសេចក្តីហិនវិនាសលោមកលើគេដោយឥតដឹងខ្លួន (៣៥:៨) |
| - ហើយឲ្យអន្ទាក់ដែលគេបានលាក់នោះ ជាប់ខ្លួនគេវិញ (៣៥:៨) |
| -សូមឲ្យគេធ្លាក់ទៅជាប់អន្ទាក់នោះ ហើយវិនាសទៅផង (៣៥:៨) |
| -សូមបំផ្លាញគំនិតគេ (៥៥:៩) |
| -ឲ្យគេនិយាយសុទ្ធតែខុសគ្នា (៥៥:៩) |
| ឲ្យគេចុះទាំងរស់ទៅក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់ (៥៥:១៥) |
| -សូមឲ្យតុរបស់គេត្រឡប់ជាអន្ទាក់ដល់គេ ហើយកាលណាគេមានសេចក្តីសុខ |

នោះសូមឲ្យប្រែជាអន្ទាក់ដល់គេ វិញ (៦៩:២២)

-ហើយឲ្យចង្កេះគេញ័រជានិច្ច (៦៩:២៣)

-សូមចាក់សេចក្ដីក្ដៅក្រហាយរបស់ទ្រង់ទៅលើគេ (៦៩:២៤)

-ហើយឲ្យសេចក្ដីក្រោធដ៏សហ័សនៃទ្រង់តាមគេទាន់ (៦៩:២៤)

-សូមឲ្យលំនៅរបស់គេត្រូវចោលស្ងាត់ ឥតមានអ្នកណាអាស្រ័យនៅក្នុងត្រសាលគេឡើយ (៦៩:២៥)

-សូមបន្ថែមទោសទៅលើទោសរបស់គេ (៦៩:២៧)

-ហើយកុំឲ្យគេចូលមកក្នុងសេចក្ដីសុចរិតរបស់ទ្រង់ឡើយ (៦៩:២៧)

-សូមឲ្យគេបានលុបចេញពីបញ្ជីជីវិតទៅ កុំឲ្យកត់នៅជាមួយនឹងពួកមនុស្សសុចរិតឡើយ (៦៩:២៨)

-សូមទ្រង់តាំងអ្នកអាក្រក់ឲ្យគ្រប់គ្រងលើវា ហើយឲ្យសាតាំងឈរនៅខាងស្ដាំវា (១០៩:៦)

-នោះសូមឲ្យវាមានទោស (១០៩:៧)

-ហើយឲ្យសេចក្ដីអធិស្ឋានរបស់វាត្រឡប់ជាអំពើបាបវិញ (១០៩:៧)

-សូមឲ្យថ្ងៃអាយុរបស់វាបានខ្លីចុះ (១០៩:៨)

-ហើយឲ្យមានម្នាក់ទៀតទទួលយកការងាររបស់វា (១០៩:៨)

-សូមឲ្យកូនចៅវាធ្វើជាមនុស្សអារាសែទាំងដើរសុំទាន ឲ្យគេរកស៊ីតាមទីច្រកល្ហករបស់គេ (១០៩:១០)

-សូមឲ្យម្ចាស់បំណុលរឹបយករបស់វាទាំងអស់ទៅ ហើយឲ្យមនុស្សដទៃដណ្ដើមយកផលនៃការរបស់វា (១០៩:១១)

-សូមកុំឲ្យមានអ្នកណាអាណិតមេត្តាដល់វាឡើយ ក៏កុំឲ្យមានអ្នកអាសូរដល់កូនកំព្រារបស់វាដែរ (១០៩:១២)

-សូមឲ្យពូជវាត្រូវផុតចេញ លុះដល់ដំណជាន់ក្រោយ សូមឲ្យឈ្មោះវាត្រូវសូន្យបាត់ទៅ (១០៩:១៣)

-សូមឲ្យព្រះយេហូវ៉ានឹងចាំពីសេចក្ដីទុច្ចរិតរបស់ពួកឰយុកោវា (១០៩:១៤)

-ហើយកុំឲ្យបាបរបស់ម្ដាយវាត្រូវលុបចេញឡើយ (១០៩:១៤)

-សូមឲ្យសេចក្តីទាំងនោះនៅចំពោះព្រះយេហូវ៉ាជានិច្ចដើម្បីឲ្យទ្រង់បានផ្តាច់សេចក្តីនឹងចាំពីគេចេញពីផែនដីទៅ (១០៩:១៥)

-ឱកូនស្រីនៃបាបីឡូនអើយ ឯងនឹងត្រូវបំផ្លាញហើយ សប្បាយហើយ អ្នកណាដែលសងដល់ឯង តាមការដែលឯងបានប្រព្រឹត្តនឹងយើង សប្បាយហើយ អ្នកណាដែលនឹងចាប់កូនតូចរបស់ឯងទៅបោកនឹងថ្មផង (១៣៧:៨-៩)

**ទីបី** អ្នកនិពន្ធបានអធិស្ឋានថា សូមឲ្យព្រះទ្រង់សងការអាក្រក់ឲ្យសមនឹងទំហំការអាក្រក់របស់ពួកគបើមិនមែន១ជា៧ដង៖

*ឯពួកមនុស្សមោហោ គេរមែងមានទុក្ខដោយព្រោះការរំលងច្បាប់ នឹងអំពើទុច្ចរិតរបស់គេ*

*(១០៩:១៧)*

សេចក្តីអាក្រក់ដែលពួកខ្មាំងសត្រូវបានប្រព្រឹត្តទាស់នឹងអ្នកនិពន្ធ ជារឿងធម្មតាចំពោះគាត់ ដូចជាសំលៀកបំពាក់ដែលគាត់បានស្លៀកអញ្ចឹង។ ពួកគេបានក្លាយជាទឹកអប់ដល់ព្រលឹងរបស់គាត់ ហើយអ្នកនិពន្ធដែលមិនត្រឹមត្រូវអធិ ស្ឋានថា សូមឲ្យសំលៀកបំពាក់កខ្វក់នេះបានតោងជាប់នឹងគាត់ជារៀងរហូតជាអ្វីដែលបណ្តាលឲ្យមានសេចក្តីរងទុក្ខយ៉ាងធំ៖

*វាបានប្រដាប់ខ្លួន ដោយការជេរប្រទេច ដូចជាពាក់អាវ ហើយការនោះក៏ចូលទៅដល់ខាងក្នុងវាដូចជាទឹក ហើយបានជ្រាបទៅក្នុងឆ្អឹងវាដូចជាប្រេង សូមឲ្យការនោះបានសំរាប់វា ដូចជាសំលៀកបំពាក់ដែលវាតែង ស្លៀកពាក់ ហើយជាខ្សែក្រវាត់ដែលវារឹតនៅចង្កេះជានិច្ចដែរ នេះហើយជារង្វាន់ដែលព្រះយេហូវ៉ាទ្រង់ប្រទាន ដល់ពួកខ្មាំងសត្រូវនៃទូលបង្គំ ហើយដល់អស់អ្នកដែលនិយាយបង្កាច់ដល់ព្រលឹងនៃទូលបង្គំដែរ (ខ១៨-២០)។*

សេចក្តីអធិស្ឋានដ៏តក់ស្លុតនៃទំនុក១៣៧ បានស្ថិតនៅក្នុងនិទ្ទេសបទនេះដែរ ព្រោះពួកបាបីឡូនបានចាប់កូនតូចរបស់ពួកអ៊ីស្រាអែលបោកនឹងថ្ម ហើយអ្នកនិពន្ធបានអធិស្ឋានថា ពួកគេនឹងត្រូវសងវិញនូវទំហំដែលគេបានធ្វើចំពោះពួកអ៊ីស្រាអែលវិញ៖

*ឱកូនស្រីនៃបាបីឡូនអើយ ឯងនឹងត្រូវបំផ្លាញហើយ សប្បាយហើយ អ្នកណាដែលសងដល់ឯង តាមការដែលឯងបានប្រព្រឹត្តនឹងយើង សប្បាយហើយ អ្នកណាដែលនឹងចាប់កូនតូចរបស់ឯងទៅបោកនឹងថ្មផង (ខ.៨-៩)។*

សីលធម៌នៃភ្នែកឲ្យធួននឹងភ្នែក ហើយធ្មេញឲ្យធួននឹងធ្មេញ ប្រហែលធ្វើឲ្យលំបាកដល់ព្រលឹងគ្រីស្ទាន តែវាជាកំរិតមួយនៃសីលធម៌សញ្ញាចាស់។ វាមិនមែនជារបស់ទាំងមូលទេ គ្រាន់តែជា១ផ្នែកប៉ុណ្ណោះ ហើយយើងពិតជាមិនអាចកោតសរសើរ១ផ្នែក នោះបានឡើយ រហូតទាល់តែយើងបានមើលឃើញរបស់ទាំងមូល។ នៅក្នុងករណីនេះ យើងត្រូវការឃើញកំរិតខ្ពស់ជាងនៃសីលធម៌សញ្ញាចាស់ ដែល សេចក្តីស្រឡាញ់របស់ព្រះ និងសេចក្តី ស្រឡាញ់ដល់អ្នកជិតខាងជាកម្រិតកំណត់នូវការប្រព្រឹត្តរបស់មនុស្ស។ ហើយយើងត្រូវទទួលស្គាល់ថា ទាំងក្នុងព្រះគម្ពីរ និង ប្រវត្តិសាស្រ្ត នៅតែមានកន្លែងឲ្យថ្កោលទោសទៅលើសីលធម៌គ្រីស្ទាន ជាសេចក្តីថ្កោលទោសដែលមិនពឹងផ្អែកលើច្បាប់នៃការសងសឹក ប៉ុន្តែលើសេចក្តីយុត្តិធម៌របស់ព្រះជាម្ចាស់វិញ។

**ទីបួន** ការបន្ទោសរបស់ពួកខ្មាំងសត្រូវ មិនបានឈរនៅតែឯងទេ តែបានចាក់ឫសជ្រៅក្នុងសេចក្តីបដិសេធព្រះផ្ទាល់។ នៅក្នុងសេចក្តីនោះ អ្នកនិពន្ធបានអធិស្ឋាន សូមឲ្យ ព្រះ ទ្រង់ដាក់ទោសដល់ពួកគេ ១ជា៧ដងវិញ៖ *"ឱព្រះអម្ចាស់អើយ ឯការដែលពួកអ្នកជិតខាងយើង ខ្ញុំបានត្មះតិះដៀលដល់ទ្រង់ នោះសូមសងទៅលើទ្រូងគេ ១ជា៧វិញ" (៧៩:១២)*

ចំណុចសំខាន់អំពីគោលការណ៍ជំនុំជំរះទាំងនេះ គឺថាអ្នកនិពន្ធមិនបានអធិស្ឋានចេញពីការព្យាបាទពិតដល់អ្នកបៀតបៀនគាត់ទេ ។ លោក Keel បាន អង្កេតឃើញថា ពួកខ្មាំងសត្រូវ ត្រូវបានអ្នកនិពន្ធពណ៌នានៅក្នុងលក្ខណៈមួយយ៉ាងច្បាស់ថា ពួកគេរស់នៅ និងប្រព្រឹត្តដោយគិតថាគ្មានព្រះទាល់តែសោះ។ ហេតុដូច្នេះ ស្ថិតនៅលើមូលដ្ឋាននេះដែលអ្នកនិពន្ធបានទូលអង្វរ ដល់ព្រះ ឲ្យដាក់ទោសដល់ពួកគេ៖ "ការប្រព្រឹត្តរបស់ពួកគេបង្កើតឲ្យមានការសង្ស័យថាគ្មានព្រះជំនុំជំរះពួកគេឡើយ"។ អ្នកនិពន្ធបានជឿថាគាត់បានអធិស្ឋានតាមព្រះហឫទ័យរបស់ព្រះ។ តាមពិត នេះជាហេតុផលដែលលោក Johannes Vos បាននិយាយថាសេចក្តីអធិស្ឋាននេះប្រហែលនៅតែត្រូវបានប្រើប្រាស់ ក្នុងការថ្វាយបង្គំរបស់គ្រីស្ទាន ៖

> *ដោយព្រោះសកម្មភាពរបស់ព្រះជាម្ចាស់ ដែលបានអធិស្ឋានសម្រាប់ បានទាស់នឹងភាពមិនត្រឹមត្រូវពិតរបស់មនុស្ស ហើយដោយព្រោះតែអ្នកអធិស្ឋានខ្លួនឯងផ្ទាល់ត្រូវបានបញ្ចេញយោបល់ដោយព្រះវិញ្ញាណបណ្តាល ដូច្នេះសេចក្តីអធិស្ឋាននោះត្រឹមត្រូវ ហើយមិនអាចជាអសីលធម៌នោះឡើយ។ វិនាសកម្មទាំងស្រុងនៃសេចក្តីអាក្រក់ រួមទាំងការបំផ្លាញមនុស្សអាក្រក់តាមរយៈការជំនុំជំរះ គឺជាអធិបតេយ្យនៃព្រះ ហើយគឺត្រឹមត្រូវ មិនត្រឹមតែអធិស្ឋានសូមឲ្យសម្រេចនូវការបំផ្លាញនេះប៉ុណ្ណោះទេ ថែមទាំងជួយឲ្យបានសម្រេច នៅពេលព្រះទ្រង់បង្គាប់ឲ្យធ្វើបែបនោះដោយព្រះអង្គផ្ទាល់។*

ការពិនិត្យពិច័យពីទំនុកតំកើងបណ្តាសាខាងលើ មិនបានធ្វើឲ្យអ្នកអានខ្លះស្កប់ចិត្តឡើយ។ ពួកគេនៅតែមានអារម្មណ៍មិនសុខស្រួលជាមួយសេចក្តីអធិស្ឋានដោយ "កំហឹង"ទាំងនេះ ហើយប្រហែលជាគួរតែមានទំនុកខ្លះមិនស្រួលដល់យើងដែរ ដែលសេចក្តីអធិស្ឋានទាំងនេះត្រូវគេអធិស្ឋាន ឬក៏ត្រូវតែអធិស្ឋានបែបនោះ។ ដោយហេតុនោះអ្នកខ្លះបានត្រូវជំរុញឲ្យស្វែងរកផលប្រយោជន៍ដែលទំនុកតំកើងទាំងនេះអាចផ្តល់ឲ្យ

។ លោក Erich Zenger បានរំឭកយើងថា ទំនុកតំកើងទាំងនេះផ្តល់នូវទស្សនៈត្រឹមត្រូវ ពីលោកិយ នេះ។ គឺថា ទំនុកតំកើងទាំងនេះនឹងមិនអនុញ្ញាតឲ្យយើងបដិសេធចោលអំពើហឹង្សានិងអំពើអាក្រក់នៃពិភពលោកដែលយើងរស់នៅនេះទេ។ ទោះបីជាគាត់មិនអាចទទួលស្គាល់ពេញលេញនូវ គតិលោកដែលបាននិពន្ធទំនុកតំកើងទាំងនេះ តែគាត់បានលើកឡើងនូវទស្សនៈបួនយ៉ាងដែលធ្វើឲ្យឲ្យទំនុកតំកើងទាំងនេះ "អាចបម្រើ" ដល់សម័យនេះ៖

1. ពួកខ្មាំងសត្រូវដែលទំនុកតំកើងទាំងនេះថ្លែងមិនមែនជាតួអង្គទេវកថា ឬអារក្សនោះទេ។ ទំនុកតំកើងទាំងនេះថ្លែងដោយហ្មត់ចត់និងន័យត្រង់ៗ។
2. តាមកំរិតមួយនៃទំនុកទាំងនេះ បង្ហាញឲ្យឃើញថាអំពើហឹង្សាគឺជា "ដំណើរខុសពីភាពដើមផ្នែករចនាសម្ព័ន្ធនៃផែនដីដែលជាទីស្នាក់អាស្រ័យនៃជីវិត អ្វីដែលធ្វើឲ្យព្រះជាម្ចាស់ទ្រង់ខ្វាល់ គឺពួកគេបានផ្តល់នូវ មនោគមន៍វិទ្យាយ៉ាងខ្លាំងដូចជាសន្យាពីសេចក្តីសុខសាន្ត និងការរំដោះឲ្យមានសេរីភាព"
3. ទំនុកតំកើងទាំងនេះឲ្យយើង យកចិត្តទុកដាក់អំពី "សំណាញ់នៃសេចក្តីក្រោធ" ដែលវាយប្រហារដល់លោកីយ និងផ្តល់នូវការឈឺចាប់ដល់មនុស្ស ជាពិសេសដល់អ្នកដែលទន់ខ្សោយ អ្នកមានជម្ងឺ អ្នករងទុក្ខ និងពួកអ្នកដែលស្ថិតនៅក្រោមការវាយប្រហារពីសំណាក់បរិស្ថានដ៏កាចសាហាវ (ឬពីមនុស្សដែលកាចសាហាវ)"
4. ទោះបីជាទំនុកទាំងនេះសំដៅអ្នកដទៃ ជាអ្នកប្រព្រឹត្តអំពើឧក្រិដ តែក្នុងពេលទន្ទឹមគ្នាអំពាវនាវឲ្យយើងប្រឈមមុខនឹងការចូលដៃក្នុងសំណាញ់នៃសេចក្តីក្រោធ។

លោក C.S. Lewis បានអង្កេតឃើញថា ចំពោះគ្រីស្ទាន ទំនុកតំកើងបណ្តាសា រំឭកយើងថា អវត្តមាននៃការឈឺចាប់ ប្រហែលជាសញ្ញានៃការប្រកាសអាសន្នមួយនៃការធ្លាក់ចុះខាងសេចក្តីសុចរិត និងសីលធម៌ បើបាត់បង់ការធ្វើឲ្យដឹងខ្លួន មានន័យថាបាត់បង់ខ្សែចងសីលធម៌របស់យើងកុំឲ្យរសាត់បាត់ហើយ។

ទោះបីជានេះប្រាកដជាអនុផលនៃទំនុកដំកើងទាំងនេះក៏ពិតមែន តែទំនុកដំកើងទាំងនេះក៏ប្រហែលជាបង្រៀនយើងនូវការមួយអំពីការអធិស្ឋាន ដែលនៅក្នុងសេចក្តីអធិស្ឋានយើងអាច "និយាយអ្វីៗគ្រប់ យ៉ាងតាមន័យត្រង់ គឺអ្វីៗគ្រប់យ៉ាង បើយើងនិយាយទៅកាន់ព្រះជាម្ចាស់" ខណៈពេលដែលចិត្តរបស់យើងស្រឡាញ់និងគោរពព្រះខ្លាំង ដែលអាចទាស់នឹងភាសាដែលទំនុកទាំងនេះប្រើ ដូចជាពាក្យដែលលោកយ៉ូបបាននិយាយទាស់នឹងព្រះដ៏មានព្រះចេស្តា នោះតើទ្រង់មិនជ្រាបពីអ្វីដែលយើងកំពុងគិតទេឬអី? តើវាមិនមែនជាការដែលស្មោះត្រង់លើសទៅទៀតទេឬអី បើ យើងដាក់ចុះការទាំងអស់នៅចំពោះទ្រង់ ហើយចែកចាយនូវអារម្មណ៍របស់យើងនៅក្នុងព្រះវត្តមានរបស់ទ្រង់ តាមរយៈអំណាចនៃសេចក្តីអធិស្ឋាន? ពិតណាស់ មានការខ្លះជាព្រំដែន ហើយនៅក្នុងព្រះជាម្ចាស់ ព្រំដែននិងភាពស្មោះត្រង់អាចគៀកស្មាទៅទន្ទឹមគ្នា។ យើងអាចសារភាពនូវអារម្មណ៍អវិជ្ជមានរបស់ យើងចេញមក ស្របពេលដែលយើងទទួលស្គាល់ថានិស្ស័យបាបរបស់យើងមិនសមរម្យនិងដាច់ចេញពីព្រះយ៉ាងណា។

ជាចុងក្រោយ អ្នកនិពន្ធមិនបានដោះស្រាយបញ្ហានោះដោយដៃរបស់គាត់ផ្ទាល់នោះទេ ប៉ុន្តែគាត់ថ្វាយទៅព្រះហស្តព្រះជាម្ចាស់វិញ។ ដើមឡើយទំនុករបស់គាត់គឺជាភាសិត "ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ការសងសឹកគឺរបស់អញ អញនឹងសងវាវិញ" Zenger បានធ្វើការកត់សំគាល់ថា "ពួកគេបានបញ្ជាក់អះអាងពីព្រះជាម្ចាស់ដោយថ្វាយពាក្យចុងក្រោយទៅព្រះ។ ពួកគេថ្វាយ ទៅកាន់ព្រះមិនមែនត្រឹមតែសេចក្តី ត្អូញត្អែអំពីស្ថានភាពទុក្ខព្រួយរបស់ពួកគេប៉ុណ្ណោះទេ តែថ្វាយសិទ្ធិដើម្បីជំនុំជម្រះទៅព្រះដើម្បីកាត់ទោស ពួកខ្មាំងសត្រូវដែលធ្វើទុក្ខដល់ ពួកគេផងដែរ។ ពួកគេបានថ្វាយគ្រប់ការទាំងអស់ទៅក្នុងព្រះហស្តរបស់ទ្រង់ សូម្បីតែអារម្មណ៍ស្អប់ និងបំពានក៏ដោយ"។

ថាតើទំនុកតំកើងបណ្តាសាអាចក្លាយជាចំណុចស្នូលនៃសេចក្តីអធិស្ឋាន ដែល យើងមានអារម្មណ៍អធិស្ឋានដោយសុខស្រួលនឹងអធិស្ឋានក៏ដោយ តែទំនុកទាំងនេះអាចរំឭកយើងថា លោកិយ នេះពេញដោយភាពអយុត្តិធម៌ តែព្រះជាម្ចាស់ទ្រង់យុត្តិធម៌ ដូច្នេះយើងរាល់គ្នាអាចទំលាក់ចុះនូចកំហុសខុស ឆ្គងរបស់អ្នកដទៃដែលបានធ្វើខុសនឹងយើងទៅក្នុងព្រះហស្តប្រកបដោយព្រះគុណរបស់ទ្រង់បាន ដូចជាយើងមានបទពិសោធពីការតស៊ូខាងគំនិតនិងពាក្យរបស់អ្នកសរសេរទំនុកតំកើងទាំងនេះ។ ដូច C.H. Spurgeon ផ្តល់យោបល់ថា "សូមកុំឲ្យយើងបរាជ័យ ក្នុងការ ដាក់ចុះនូវស្ថានភាពរបស់យើងទៅក្នុងព្រះហស្តរបស់ទ្រង់ឡើយ។ ជំនួយដែលមកពីមនុស្សគឺឥតប្រយោជន៍ទទេ ប៉ុន្តែជំនួយដែលប្រកបដោយប្រសិទ្ធភាពនោះគឺមកពីឋានសួគ៌វិញ"។ ការនេះនឹងដឹកនាំយើងនៅក្នុងផ្លូវដ៏វែង ឆ្ងាយសំដៅឆ្ពោះទៅកាន់សីលធម៌នៃព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានហៅយើងមកឲ្យស្រឡាញ់ដល់ខ្មាំងរបស់យើង និង អធិស្ឋានឲ្យពួកគេវិញ។